**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 21-Oct-2014, 11:13
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**ចម្លើយ និងចម្លើយតបរបស់ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន ទៅនឹង *"ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខសំណុំរឿង 002/01 និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប"***

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរិវឌ្ឍ

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

កញ្ញា អ៊ូច ស្រីផាត់

កញ្ញា Cécile ROUBEIX

លោក Clément BOSSIS

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្ដីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្ដីលោក ខៀវ សំផន ("មេធាវីការពារក្ដី") បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ("សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ")[1]។

២. នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានស្នើអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") សុំបន្ថែមចំនួនទំព័រ និងពន្យាររយៈពេលកំណត់នៃការដាក់សារណាបណ្ដឹងសាទុក្ខ[2]។

៣. នៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅមេធាវីការពារក្ដី និងបានស្នើសុំបន្ថែមចំនួនទំព័រ និងរយៈពេលកំណត់ដូចគ្នាទៅនឹងសំណើសុំរបស់មេធាវីការពារក្ដី សម្រាប់ការឆ្លើយតបរបស់ខ្លួនទៅនឹងសារណាបណ្ដឹងសាទុក្ខ[3]។

៤. នៅថ្ងៃនេះ ដើម្បីឱ្យចំណេញពេលវេលា និងទទួលបានសេចក្ដីសម្រេចពីតុលាការកំពូលឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន មេធាវីការពារក្ដីសូមឆ្លើយ និងឆ្លើយតបទៅនឹងចម្លើយ[4] និងចម្លើយតប[5]

---

[1] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E313/2/1** ("សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ")។

[2] ការស្នើសុំជាបន្ទាន់របស់លោក ខៀវ សំផន សុំពន្យាពេលកំណត់ និងបង្កើនចំនួនទំព័រ នៅក្នុងសារណាបណ្ដឹងសារទុក្ខ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **F7**។

[3] ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **F7/1** (ការបកប្រែសំណើរនេះជាភាសាបារាំង ត្រូវបានស្នើសុំរួចមកហើយ ប៉ុន្តែឯកសារនេះនៅតែមិនទាន់ត្រូវបានបកប្រែ)។

[4] មាត្រា ៨.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្ដីណែនាំអនុវត្ត")។

[5] មាត្រា ៨.៣ នៃសេចក្ដីណែនាំអនុវត្ត។

ចម្លើយ និងងចម្លើយតបរបស់ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន ទៅនឹង"*ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប*"

ក្នុងពេលតែមួយទៅនឹងសារណារបស់សហព្រះរាជអាជ្ញា។ ប៉ុន្តែ មេធាវីការពារក្ដីសុំរក្សាសិទ្ធិបំពេញបន្ថែមចម្លើយតបនេះ (ក្នុងករណីចាំបាច់) នៅពេលទទួលបានសារណារបស់សហព្រះរាជអាជ្ញា បកប្រែជាភាសាបារាំង ក្នុងរយៈពេលកំណត់តម្រូវដោយច្បាប់។

៥. ជារួម សហព្រះរាជអាជ្ញាបានប្រឆាំងនឹងសំណើសុំរបស់មេធាវីការពារក្ដីក្រោមលេសពន្លឿនដំណើរការនីតិវិធី ដោយបានស្នើដោយឥតអៀនខ្មាស សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ក្នុងការដាក់ចម្លើយតបរបស់ខ្លួន ដែលសំដៅធ្វើឲ្យយឺតយ៉ាវយ៉ាងជាក់ស្ដែងដល់ដំណើរការនីតិវិធី។

៦. សារណាទាំងដប់ទំព័រតាមបែបសន្ទតខុសទំនង និងមានចរិតមើលស្រាលលើចេតនា និងការងាររបស់មេធាវីការពារក្ដី របស់សហព្រះរាជអាជ្ញា បង្ហាញឲ្យឃើញពីកង្វះភាពម៉ឺងម៉ាត់របស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាស្ថិតនៅក្នុងស្ថានភាពអនុគ្រោះមួយដើម្បីបរិហារពីការខ្វះខាតវិជ្ជាជីវៈដោយសន្ទតរបស់មេធាវីការពារក្ដី ខណៈខ្លួនពុំមានសមត្ថភាពបង្ហាញសូម្បីតែហេតុផលគតិយុត្តណាមួយ ដើម្បីស្នើសុំបដិសេធសំណើទាំងឡាយរបស់មេធាវីការពារក្ដី ដែលជាសំណើផ្អែកលើការអនុវត្តជាអន្តរជាតិ។

៧. ម្យ៉ាងវិញទៀត សំណើរបស់សហព្រះរាជអាជ្ញាផ្ទាល់ គ្រាន់តែត្រូវបានសំអាងដោយភាពត្រូវគ្នាសាមញ្ញមួយតាមបែបគណិតវិទ្យា ដែលគ្មាននៅក្នុងប្រព័ន្ធគតិយុត្តណាមួយ តែប៉ុណ្ណោះ។ ក៏ប៉ុន្តែ “ទទ្បីករណ៍”នេះ ដែលត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងសារណាមុនៗ ត្រូវបានបដិសេធចោលដោយតុលាការកំពូលរួចមកហើយ[6]។ ទោះបីជាយ៉ាងនេះក្ដី សហព្រះរាជអាជ្ញានៅតែចចេសក្នុងភាពគួរឲ្យអស់សំណើច

[6] សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី សុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណានៃបណ្ដឹងសាទុក្ខ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **F3/3** កថាខណ្ឌ ១០។ ចម្លើយ និងចម្លើយតបរបស់ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន ទៅនឹង“*ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប*”

និងស្តែងឲ្យឃើញពីអសមត្ថភាពរបស់ខ្លួនក្នុងការគាំទ្រសំណើសុំទាំងឡាយរបស់ខ្លួន និងក្នុងការបង្ហាញពីហេតុផលគតិយុត្តនានាដែលមានសុពលភាព។

៨. ដូច្នេះ មេធាវីការពារក្តីនៅតែរក្សាសំណើរបស់ខ្លួនយ៉ាងមុតមាំ ក្នុងការសុំដាក់សារណាបណ្តឹងសាទុក្ខចំនួន ៣០០ ទំព័រជាភាសាបារាំង និងចំនួនទំព័រសមមូលជាភាសាខ្មែរ ក្នុងរយៈពេល ១៧៤ ថ្ងៃ ក្រោយពីការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ (រយៈពេល ៩០ ថ្ងៃ សម្រាប់ការសរសេរ បូកនឹងចំនួន ៨៤ ថ្ងៃ សម្រាប់រយៈពេលបកប្រែ)។ មេធាវីការពារក្តីនៅតែទទូចដាក់សារណានេះជាពីរភាសាការងារក្នុងពេលតែមួយ និងសូមបញ្ជាក់ថា សហព្រះរាជអាជ្ញានឹងមិនលើកឡើងនូវកាលៈទេសៈពិសេសណាមួយ (ឬក៏ការចំណេញពេលវេលាណាមួយ ពាក់ព័ន្ធនឹងពេលវេលាកំណត់)[7] យកមកអះអាងផ្ទុយពីនេះឡើយ។

៩. មេធាវីការពារក្តីប្រឆាំងដាច់ខាតទៅនឹងសំណើសុំគ្មានរបស់សហព្រះរាជអាជ្ញា ដែលជាមូលហេតុតែមួយគត់បង្កជាឧបសគ្គដល់ការពន្លឿនដំណើរការនីតិវិធី។ អនុលោមតាមការអនុវត្តជាអន្តរជាតិ ប្រសិនបើតុលាការកំពូលឯកភាពលើសំណើរបស់មេធាវីការពារក្តី នោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណារបស់ម្ចាស់បណ្តឹងសាទុក្ខទាំងពីររូប គួរត្រូវបានកម្រិតមកត្រឹមចំនួន ៤០០ ទំព័រ (តែពុំមែន ៦០០ ទំព័រនោះឡើយ)[8] និងត្រូវដាក់នៅក្នុងរយៈពេល ៤៨ ថ្ងៃ ពុំគិតពីរយៈពេលបកប្រែ (តែពុំមែន ៩០ ថ្ងៃ ដោយមិនគិតរយៈពេលបកប្រែនោះទេ)

---

[7] សូមមើល ការស្នើសុំជាបន្ទាន់របស់លោក ខៀវ សំផន សុំពន្យាពេលកំណត់ និងបង្កើនចំនួនទំព័រនៅក្នុងសារណាបណ្តឹងសារទុក្ខ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ F7 កថាខណ្ឌ ២០ ដល់ ២២។

[8] សូមមើល ចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងករណី ០០២/០១ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ F3/2 កថាខណ្ឌ ២ និងកំណត់សម្គាល់ជើងទំព័រលេខ ៦។ ចម្លើយ និងងចម្លើយតបរបស់ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ទៅនឹង“*ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប*”

ដោយចាប់គិតពីថ្ងៃទទួលសេចក្តីជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខ[9]។ ដូច្នេះ ការសម្រេចឯកភាពលើសំណើគ្មានហេតុផលត្រឹមត្រូវរបស់សហព្រះរាជអាជ្ញា នឹងនាំឱ្យមានការពន្យារពេលវេលាដោយគ្មានមូលហេតុចំនួន ៩៨ ថ្ងៃ នៅក្នុងដំណើរការនីតិវិធីបណ្តឹងសាទុក្ខ (៤២ ថ្ងៃ សម្រាប់ការសរសេរ បូកនឹងរយៈពេល ៥៦ ថ្ងៃ សម្រាប់ការបកប្រែឱ្យបាន ២០០ ទំព័រ) ហើយដូច្នេះ វាពិតជា“ *មិនបាននាំមកនូវដំណោះស្រាយចំពោះដំណើរការនីតិវិធីឱ្យបានទាន់ពេលនោះទេ*”[10]។

## ផ្អែកតាមសំអាងហេតុខាងលើនេះ

១០. មេធាវីការពារក្តីលោក ខៀវ សំផន ស្នើតុលាការកំពូល មេត្តា៖

- **អនុញ្ញាត**ឱ្យមេធាវីការពារក្តីដាក់សារណាបណ្តឹងសាទុក្ខ ចំនួន ៣០០ ទំព័រ ជាភាសាបារាំង និងចំនួនទំព័រសមមូលចាំបាច់ជាភាសាខ្មែរ ក្នុងរយៈពេល ១៧៤ ថ្ងៃ បន្ទាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។
- **បដិសេធ**សំណើរសុំរបស់សហព្រះរាជាអាជ្ញា ដែលសំដៅធ្វើឱ្យយឺតយ៉ាវដល់ដំណើរការនីតិវិធី។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ | |
| | មេធាវី Arthur VERCKEN | រាជធានីភ្នំពេញ | |

[9] សូមមើល ចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងករណី ០០២/០១ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ F3/2 កថាខណ្ឌ ៣ និងកំណត់សម្គាល់ជើងទំព័រលេខ ៩។

[10] ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ F7/1 កថាខណ្ឌ ២១។ ចម្លើយ និងងចម្លើយតបរបស់ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ទៅនឹង“*ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប*”